ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០១០......សហវ.......

# សារាចរ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី១

អនុវត្តតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមក្នុងការបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) និងបានដាក់ឱ្យអនុវត្តជាផ្លូវការនៅរដ្ឋបាលកណ្តាលចំនួន ២៣ (ម្ភៃបី) ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញចំនួន១៨ (ដប់ប្រាំបី) នៅរាជធានី ខេត្តទាំង ២៥ (ម្ភៃប្រាំ)។ បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តផ្តួចផ្តើមក្នុងការបង្កើតប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) ផ្សារភ្ជាប់នឹងប្រព័ន្ធ NRMIS ដើម្បីផ្តល់ជាជម្រើសបន្ថែមដល់សាធារណជនក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ដែលនឹងដាក់ឱ្យអនុវត្តជាជំហានៗ។

នៅក្នុងជំហានទី១ ការបង់ចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក នឹងដាក់ឱ្យអនុវត្តសម្រាប់ក្រសួង ចំនួន០៣ (បី) គឺ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រួមទាំងមន្ទីរជំនាញនៃក្រសួងទាំង០៣ (បី) នៅទូទាំងប្រទេស។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធទូទាត់អេឡិចត្រូនិក សម្រាប់ការបង់ចំណូលមិនមែនសារពើពន្ធ ជាមួយនឹងក្រសួង ស្ថាប័ន រួមទាំងមន្ទីរ អង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងទៀត នៅក្នុងជំហានបន្តបន្ទាប់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំ ក្រសួង និងមន្ទីរជំនាញរាជធានី ខេត្ត ដែលអនុវត្តប្រព័ន្ធទូទាត់អេឡិចត្រូនិក ជំហានទី១ ដូចមានរៀបរាប់ខាងលើ ដូចតទៅ៖

១. ក្រសួងទាំង០៣ (បី) ខាងលើ ត្រូវបើកគណនីចរន្តចំនួន ០១ (មួយ) (ជារៀល) ឬ ០២ (ពីរ) (ជារៀល និងដុល្លារអាមេរិក) ជាមួយនឹងធនាគារពាណិជ្ជដៃគូ (ធនាគារ អេស៊ីលីដា ភីអិលស៊ី ឬ ធនាគារ កាណាឌីយ៉ា ក.អ) តាមស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួងសាមី (ប្រមូលជារូបិយបណ្ណរៀល ឬ ដុល្លារអាមេរិក) ដើម្បីទទួលសាច់ប្រាក់ដែលជាចំណែកប្រាក់រង្វាន់ពីការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលក្រសួង និងមន្ទីរជំនាញសាមីប្រមូលបាន។ រាល់ការបើកគណនីចរន្តទាំងនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការស្នើសុំរបស់ក្រសួងសាមី។

២. ក្រសួង និងមន្ទីរជំនាញ ត្រូវបោះពុម្ពវិក្កយបត្រដែលមាន QR កូដចេញពីប្រព័ន្ធ NRMIS ប្រគល់ជូនអតិថិជន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ដែលបង់ចំណូលមិនមែនសារពើពន្ធជូនក្រសួង និងមន្ទីរជំនាញ ដោយអតិថិជនអាចជ្រើសរើសវិធីទូទាត់តាមប្រព័ន្ធទូទាត់អេឡិចត្រូនិក ដោយប្រើប្រាស់កម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ធនាគារពាណិជ្ជដៃគូ ឬ កម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (NRMIS App)។

៣.ក្រសួង និងមន្ទីរជំនាញ ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធ ដើម្បីផ្សព្វផ្សាយអំពីជម្រើសក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ដោយការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក។

៤.សម្រាប់ការបង់ចំណូលពីសេវាសាធារណៈមានទំហំទឹកប្រាក់ចាប់ពី ១ ០០០ ០០០(មួយលាន)រៀល ឡើងទៅក្រសួង និងមន្ទីរជំនាញ ឬ អតិថិជនត្រូវបានលើកទឹកចិត្តឱ្យអនុវត្តការបង់ចំណូលតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក។ ដោយឡែក ចំពោះចំណូលពីសេវាសាធារណៈមានទំហំទឹកប្រាក់ក្រោម ១ ០០០ ០០០ (មួយលាន)រៀល អាចប្រមូលនិងបង់ដោយរជ្ជទេយ្យករចំណូល។

៥.ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត អាចអនុវត្តការបង់ចំណូលតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក ដោយមិនកំណត់ទំហំទឹកប្រាក់។

៦.ចំពោះចំណូលដែលទទួលបានតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សំរាកក្រសួង និងមន្ទីរជំនាញត្រូវកំណត់យកកាលបរិច្ឆេទបញ្ចប់វិក្កយបត្រនៅថ្ងៃដំបូងនៃថ្ងៃចូលធ្វើការធម្មតា។ ចំពោះរូបិយបណ្ណជាដុល្លារអាមេរិក ការកត់ត្រាចំណូលត្រូវកំណត់យកអត្រាប្តូរប្រាក់តាមថ្ងៃដំបូងនៃថ្ងៃចូលធ្វើការធម្មតា។

ទទួលបានសារាចរនេះ ក្រសួង និងមន្ទីរជំនាញរាជធានី ខេត្ត ខាងលើ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងដែលពាក់ព័ន្ធ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- រតនាគាររាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្តដែលពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ